# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 622

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : គម្រោងលើកកម្ពស់និងអភិវឌ្ឍមន្ទីរពិសោធន៍ផលិតផលកសិកម្មនិងចំណីអាហារកម្ពុជា

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/01/22

កាលបរិច្ឆេទបញ្ចប់គម្រោង 31/12/24

៣. ចំណាយគម្រោងសរុប $5,610,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

RESPONSIBLE UNIT Department of Agro-Industry

អង្គភាពទទួលខុសត្រូវ នាយកដ្ឋានកសិ-ឧស្សាហកម្ម

៥. ស្ថានភាពគម្រោង គម្រោងដែលបានលុបចោល

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ស្វែងរកម្ចាស់ជំនួយ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី២- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងខាងលើនេះ នឹងរួមចំណែកក្នុងការជម្រុញគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជារួមមាន៖

១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជា

២. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៣. គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ របស់រាជរដ្ឋាភិបាលកម្ពុជា

៤. គោលការណ៍ត្រួតពិនិត្យគុណភាព សុវត្ថិភាព អនាម័យ និងភូតគាមអនាម័យលើផលិតផលកសិកម្ម និងចំណីអាហារដើមកំណើតពីសត្វ រុក្ខជាតិ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៥. គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ នៃអង្គការសហប្រជាជាតិ

៦. ផែនការយុទ្ធសាស្ត្រឆ្នាំ ២០១៧-២០៣០ នៃនាយកដ្ឋានកសិ-ឧស្សាហកម្ម

៧. គោលនយោបាយនាំចេញ-នាំចូលលើផលិតផលកសិកម្ម និងចំណីអាហារទៅប្រទេសចិនប្រកបដោយគុណភាព និងសុវត្ថិភាពល្អប្រសើរ (ពិធីសារចំនួនបីដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចុះហត្ថលេខាជាមួយសាធារណៈរដ្ឋប្រជាមានិតចិន)

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? **មិនគាំទ្រ**

**១១. វិស័យ** ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

កសិកម្ម និងការគ្រប់គ្រងដីធ្លី Research and Extension Services

**១២. ទីតាំងអនុវត្តគម្រោង** ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

រាជធានីភ្នំពេញ, តាកែវ, កំពង់ស្ពឺ, ត្បូងឃ្មុំ , ស្វាយរៀង,

**១៣. គោលបំណងរបស់គម្រោង** ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

គោលបំណងរួមមាន៖
១. ធានាបាននូវសុខភាព សុខុមាលភាព និងសុខុដុមរមនាប្រជាពលរដ្ឋកម្ពុជា
២. ធានាការគ្រប់គ្រងបាននូវគុណភាព សុវត្ថិភាព និងភាពគ្មានហានិភ័យចំពោះការប្រើប្រាស់ផលិតផលកសិកម្ម និងចំណីអាហារ
៣. លើកកម្ពស់កិត្យានុភាពជាតិក្នុងឆាកអន្តរជាតិ លើការនាំចេញផលិតផលកសិកម្ម ប្រកបដោយគុណភាព និងសុវត្ថិភាព
៤. កំណែទម្រង់ស៊ីជម្រៅលើការអភិវឌ្ឍន៍ធនធានមនុស្ស ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ
៥. លុបបំបាត់កម្រៃក្រៅផ្លូវការ តាមរយៈការប្រតិបត្តិការយន្តការ "ច្រកចេញ-ចូលតែមួយ" លើការផ្តល់សេវាសាធារណៈក្នុងការវិភាគលើផលិតផលកសិកម្ម និងស្បៀងអាហារ
៦. កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋដោយតម្លៃបន្ថែមតាមរយៈគុណភាព និងសុវត្ថិភាព

**១៤. ការពិពណ៌នាអំពីគម្រោង** ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

សមាសភាគគម្រោងរួមមាន៖
សកម្មភាពទី១៖ ពង្រឹង បណ្តុះបណ្តាល និងកសាងសមត្ថភាពធនធានមនុស្ស
សកម្មភាពទី២៖ ពង្រឹង និងពង្រីកសកម្មភាពអធិការកិច្ចធ្វើការត្រួតពិនិត្យ វិភាគគុណភាព សុវត្ថិភាព អនាម័យ និងភូតគាមអនាម័យផលិតផលកសិកម្ម ចំណីអាហារ និងទំនិញដែលមានដើមកំណើតពីផលិតផលកសិកម្ម
សកម្មភាពទី៣៖ ពង្រឹងយន្តការអនុវត្តច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន
សកម្មភាពទី៤៖ ពង្រីកការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍
សកម្មភាពទី៥៖ រៀបចំឯកសារ លិខិតបទដ្ឋានគតិយុត និតិវិធីប្រតិបត្តិស្តង់ដារ និងបច្ចេកទេស

**១៥. យុត្តិកម្មលើគម្រោង** ( បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស )

គម្រោងនេះ ជាអាទិភាពយកចិត្តទុកដាក់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា ផងដែរ។ បញ្ហាសុខភាពរបស់ប្រជាជន ជាវត្ថុបំណងរបស់មន្ទីរពិសោធន៍នានាលើសកលលោក លើការប្រើប្រាស់ ផលិតផលដែលមានគុណភាព និងសុវត្ថិភាពខ្ពស់។ ប្រាក់ចំណូលពីការនាំចេញផលិតផលដែលមានគុណភាព និងសុវត្ថិភាពខ្ពស់ នឹងត្រូវបានកើនឡើងជាបន្តបន្ទាប់។

**១៦. ផលប្រយោជន៍របស់គម្រោង** ( រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង )

អ្នកពាក់ព័ន្ធរួមមាន៖
១. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖ នាយកដ្ឋានកសិ-ឧស្សាហកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត
២. កសិករ អ្នកប្រមូលទិញ អ្នកលក់រាយ
៣. អ្នកនាំចេញ-នាំចូល ក្រុមហ៊ុននានា

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **គ្មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទាន់ចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះ នឹងចូលរួមកាត់បន្ថយភាពក្រីក្របានយ៉ាងគួរកត់សម្គាល់តាមរយៈការបង្កើនតម្លៃបន្ថែមពីគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្ម ស្បៀងអាហារ និងទំនិញដែលមានដើមកំណើតពីកសិកម្ម។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**មានយ៉ាងហោចណាស់ ៣០ភាគរយក្នុងមួយឆ្នាំនៃស្ត្រី ត្រូវបានចូលរួមសកម្មភាពអនុវត្តន៍ជាមួយគម្រោងនេះ។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**តាមរយៈមន្ទីរពិសោធន៍ដែលត្រូវបានកសាងក្រោមជំនួយរបស់សាធារណៈរដ្ឋប្រជាមានិតដល់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរពិសោធន៍ដែលបំពាក់ទៅដោយសម្ភារៈ និងឧបករណ៍ទំនើប នេះនឹងចូលរួមចំណែកយ៉ាងសកម្មជាមួយការអនុវត្តនូវយុទ្ធសាស្ត្ររបស់ខ្លួននាពេលខាងមុខនេះ។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**គ្មាន**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

គ្មាន

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 1,271.6 | 1,271.6 | 1,271.6 | 3,814.8 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 430.8 | 430.8 | 430.8 | 1,292.4 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 480.8 | 480.8 | 480.8 | 1,442.4 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 360.0 | 360.0 | 360.0 | 1,080.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 650.6 | 636.6 | 508.0 | 1,795.2 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 400.0 | 400.0 | 400.0 | 1,200.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 122.6 | 122.6 | 0.0 | 245.2 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 76.0 | 62.0 | 56.0 | 194.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 52.0 | 52.0 | 52.0 | 156.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 1,922.2 | 1,908.2 | 1,779.6 | 5,610.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្ដែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្ដល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 1,922.2 | 1,908.2 | 1,779.6 | 5,610.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: